# ដំណាំត្រសក់ចំណារ

## I. ស្ថានភាពទូទៅ

ដំណាំត្រសក់ត្រូវបានគេជឿជាក់ថា មានប្រភពនៅប្រទេសឥណ្ឌា ក្រោយមកក៏រីករាលដាលទៅប្រទេសអេស៊ីប ប្រទេសក្រិច ចិន ឥណ្ឌូនេស៊ី ប្រទេសថៃ និងនៅទ្វីបអាមេរិក ។





ដំណាំប្រភេទនេះ គេចាត់បញ្ចូលទៅក្នុងដំណាំត្រូវការអាកាសធាតុក្ដៅមធ្យមចន្លោះ ១៨-៣០ºC

- ត្រសក់ចំណារស្ថិតក្នុងលំដាប់គ្រួសារគូកូប៊ីតាសេ ។ គេចែកចេញជាពីរប្រភេទ គឺប្រភេទសំបករលោង និង សំបកគ្រើម។ វាជាប្រភពនៃវីតាមីន និងសារធាតុរ៉ែផ្សេងៗក្នុងទម្ងន់១០០ក្រាមដែលអាចបរិភោគបានផ្លែខ្ចី ដូចជាៈ

| សារធាតុសំខាន់ៗ | ក្នុងទម្ងន់១០០ក្រាមដែលអាចបរិភោគបាន |
|---|---|
| ទឹក | ៩៦,៣ក្រាម |
| ប្រូតេអ៊ីន | ០,៤៤ក្រាម |
| ប្រេងខ្លាញ់ | ០,៥ក្រាម |
| ថាមពល | ១៣គីឡូកាឡូរី |
| កាល់ស្យូម | ១០មីលីក្រាម |
| ផូស្វាត | ២៥មីលីក្រាម |
| ដែក | ១,៥មីលីក្រាម |
| វីតាមីនសេ | ៧មីលីក្រាម |

## II. បច្ចេកទេសដាំដុះ

ដើម្បីទទួលបានទិន្នផលពីការដាំដុះដំណាំត្រសក់ក៏ដូចដំណាំឯទៀតដែរ ត្រូវមានការងារច្រើនដែលត្រូវអនុវត្ត ដូចតទៅៈ

### *១.ការជ្រើសរើសពូជ*

ការជ្រើសរើសពូជជាកត្តាសំខាន់បំផុតនៅក្នុងការដាំដុះព្រោះពូជមានលក្ខខណ្ឌផ្សេងៗពីគ្នា ហើយត្រូវបានចែកចេញជា ៣ប្រភេទដូចតទៅ ៖







- *ពូជស្រាល:* ពូជនេះមានអាយុកាលលូតលាស់ខ្លីគឺប្រមាណពី <u>**៣៥-៤០ថ្ងៃ**</u>ក្រោយដាំ ភាគច្រើនគឺផ្លែល្អិតតូចៗជាចង្កោមៗមានបន្លាច្រើនជួរតាមបណ្ដោយនៃផ្លែទទឹងផ្លែមិនលើស ១,៥ស.ម ប្រវែងជាមធ្យម ៨-១០ ស.ម។ សន្លឹកល្អិតដើមតូចផ្កាឈ្មោលច្រើនតាមថ្នាំងនៃដើម ហើយមានរោមក្រាស់លើផ្ទៃស្លឹក និងដើមគ្រាប់តូចល្អិតស្រួចៗ ហើយខ្លីទម្ងន់ ១០០គ្រាប់មានចំនួន ២,៥-៤ ក្រាម ប្រភេទនេះគេឲ្យឈ្មោះថា **ត្រសក់បន្លា ឬត្រសក់ជ្រក់**។





- *ពូជកណ្ដាល:* ពូជនេះមានអាយុកាលលូតលាស់មធ្យម គឺប្រមាណពី <u>**៤០-៥០ថ្ងៃក្រោយដាំ**</u>។ ផ្លែភាគច្រើនមានព័ណ៌បៃតងស្រាល ផ្នែកខាងគូទមានព័ណ៌លឿងខ្ចី ផ្លែច្រើនរាយៗមិនចង្កោម ទទឹងផ្លែមាន ប្រវែង ៣-៤ស.ម បណ្ដោយផ្លែប្រវែងពី ១០-១៣ស.ម រាងរបស់ផ្លែវាធំកណ្ដាលតូចក្បាល និងកន្ទុយ ពូជនេះកសិករភាគច្រើនដាំនៅតាមសួនបន្លែ មិនមានលក្ខណៈទ្រង់ទ្រាយជាផលិតកម្មធំៗឡើយ ព្រោះទិន្នផលរាប់ពី <u>**៦-៨តោនក្នុង១ហិកតា**</u>។ លក្ខណៈសំគាល់គឺ ស្លឹកធំ ស្តើងរាងមូល រោមខ្លីៗមានព័ណ៌បៃតងធម្មតាគ្រាប់សំប៉ែតធំខ្លី ។

- *ពូជធ្ងន់:* ពូជនេះមានអាយុកាលលូតលាស់វែងប្រមាណពី **៥០-៧០ថ្ងៃក្រោយដាំ**។ ផ្លែរបស់វាទ្រវែងមានព័ណ៌បៃតងចាស់ប្រមាណ ២/៣ នៃប្រវែងផ្លែ ។ មានថ្នាំងរង្វើលបែកមែកមធ្យម ស្លឹកធំក្រាស់ហើយស្រួច

មានរោមរឹងទទឹងផ្លែជាមធ្យម ៣,៥ស.ម ប្រវែងជាមធ្យម ១២-២០ស.ម រូបសណ្ឋាននៃគ្រាប់ ទ្រវែងស្រួចកំប៉ោងកណ្តាលទម្ងន់ ១០០គ្រាប់ពី**៣,៥-៥,៥ក្រាម** ច្រើនដាំនៅខេត្តកណ្តាល កំពង់ឆ្នាំង និងកំពង់ចាម ។ ត្រសក់មិនមែនជាដំណាំប្រកាន់រដូវឡើយ ប៉ុន្តែពូជត្រសក់ក្រោយពីសំរាំងគ្រាប់ ហើយត្រូវការសំរាករយៈពេលពី **៤-៦ខែ ទើបអាចដាំដុះបាន** ។ លក្ខណៈពិសេសមួយទៀតគឺបច្ចុប្បន្នមានពូជ ២ប្រភេទ គឺពូជគ្មានជំនាន់អាចដាំបានហើយទុកពូជបាន ប៉ុន្តែពូជបង្កាត់មិនអាចទុកពូជបានឡើយ ។ សេចក្តីត្រូវការពូជសម្រាប់ដាំលើផ្ទៃដី១ហ.ត គឺ **៣,៥ ទៅ ៥គក្រ** អាស្រ័យទៅតាមភាគរយដំណុះ និង ចន្លោះគុម្ពនៃការដាំ ។

### *២.ការជ្រើសរើសរដូវ*

- សម្រាប់លក្ខខណ្ឌប្រទេសកម្ពុជា ដំណាំត្រសក់មិនមែនជាដំណាំដែលប្រកាន់រដូវឡើយ វាអាចដុះលូតលាស់បានចន្លោះសីតុណ្ហភាពពី ២០-៣០°C ។ ប៉ុន្តែរដូវសមស្របបំផុតគឺនៅចុងរដូវវស្សាចាប់ពី ខែតុលា ដល់ខែកុម្ភៈ ព្រោះក្នុងអំឡុងពេលនោះត្រសក់អាចលូតលាស់ល្អ ទិន្នផលខ្ពស់បណ្តាលមកពីកត្តា សីតុណ្ហភាពចុះទាប សំណើមបរិយាកាសខ្ពស់ ភ្លៀងមិនអូសបន្លាយសីតុណ្ហភាពដីប្រែប្រួលទាបរយៈពេល ពន្លឺថ្ងៃមានកំរិតសមស្រប ។ ប៉ុន្តែត្រសក់ជួបកត្តាលំបាកជាច្រើនចាប់ពីខែមីនា ដល់ខែឧសភា គឺសត្វល្អិត ជម្ងឺបំផ្លាញច្រើនបណ្តាលមកពីលក្ខខណ្ឌអាកាសធាតុមិនសមស្របធ្វើឲ្យត្រសក់មានទិន្នផលទាប ។ តែនៅរដូវវស្សាវិញចាប់ពីខែមិថុនា ដល់ខែកញ្ញា ត្រសក់ច្រើនជួបជម្ងឺបំផ្លាញច្រើនជាងសត្វល្អិតបណ្តាលមកពីសំណើមដី និងសីតុណ្ហភាពដីប្រែប្រួល ។

### *៣.ការជ្រើសរើស និងរៀបចំដី*

- ***ការជ្រើសរើសដី :*** ត្រសក់ត្រូវការដីមានជីជាតិគ្រប់គ្រាន់ សំបូរទៅដោយសារធាតុចិញ្ចឹម និងបន្ទុកខ្យល់គ្រប់គ្រាន់សម្រាប់ត្រសក់ គឺដីប្រភេទដីល្បប់មាត់ស្ទឹង បឹង ទន្លេ និងដីល្បាយខ្សាច់មិនដក់ទឹកក្រោយពេលភ្លៀងធ្លាក់កាលណាទឹកដក់លើសពី ៤ម៉ោងឡើងទៅ ធ្វើឲ្យត្រសក់ងាយកើតជម្ងឺទុំស្លឹក។ ក្រៅពីនោះវាអាចលូតលាស់ល្អដែរនៅលើប្រភេទដីក្រហម និងដីខ្មៅក្នុងតំបន់ខ្ពង់រាប ប៉ុន្តែដីឥដ្ឋ ឬដីជូរត្រសក់លូតលាស់មិនល្អឡើយ។ កាលណាដីដែលធ្លាប់ដាំដំណាំប្រភេទអំបូរត្រសក់ជាច្រើនលើករួចមកគេត្រូវបន្ថែមជីលាមកសត្វជាច្រើនតោនក្នុង ១ហិកតា ចន្លោះពី ២០-៣០តោន។ ដីដែលសមស្របខ្លាំងមានប៉េហាស់ ៦,៥-៧,៥ កាលណាប៉េហាស់**ទាបជាង៤** ត្រូវផ្អាកការដាំត្រសក់រយៈពេល ១-២ឆ្នាំ ត្រូវដាំដំណាំអំបូរសណ្តែកដើម្បីកែលំអដី ។
- ***ការរៀបចំដី :*** ត្រូវរាស់ប្រមូលយកស្មៅនិងដំណាំផ្សេងៗពីរដូវមុនចេញ ភ្ជួរហាលដីលើកទី១ ឲ្យជ្រៅ ត្រឡប់ស្រទាប់ដីពីក្រោមឡើងលើ និងហាលដីឲ្យបានច្រើនសប្តាហ៍ក្នុងគោលបំណងបន្ថយនូវភ្នាក់ងារចម្លងជម្ងឺ និងសត្វ ល្អិត ព្រមទាំងឲ្យស្មៅចង្រៃងាប់ ជាពិសេសគឺប្តូរទម្រង់ដីនិងពង្រាយជីជាតិ ។ ការភ្ជួរ ត្រូវធ្វើឲ្យបាន ២-៣លើក មុននឹងលើករងដាំដុះ ។ ការលើករងសម្រាប់ដាំគឺអាស្រ័យទៅតាមវិធីដាំនិងជីជាតិរបស់ដី។ កាលណាដាំដោយ ដោតចំណារបញ្ឈរទទឹងរងត្រូវមានប្រវែង ១២០ស.ម កំពស់រង ២៥-៣០ស.ម ។ ប៉ុន្តែបើដាំឲ្យវារនៅលើដីទទឹងរងមានប្រវែង ៨០ ទៅ ១០០ស.ម តែការដាំតាមវិធីនេះត្រសក់មានផ្លែចំនួនតិចទិន្នផលទាប។ នៅក្នុងលក្ខខណ្ឌអាកាសធាតុក្តៅ ដីរក្សាសំណើមគ្របដីមុនពេលដាំដើម្បីបន្ថយកំដៅដីស្មៅរក្សាសំណើមបានយូរនិងឲ្យ ដីធូរមិនហាប់កាលណាដីហាប់បណ្តាលឲ្យបន្ទុកខ្យល់មិនគ្រប់គ្រាន់ និងប្រវែងឫសចាក់បានតិច ។

*៤.វិធីសាស្ត្រដាំដុះ*

មុននឹងដាំ ត្រូវយកគ្រាប់ពូជមកដាក់ហាលថ្ងៃឲ្យក្ដៅរយៈពេល១-២ម៉ោង បន្ទាប់មកយកទៅត្រាំទឹករយៈពេល ៤ ទៅ៥ម៉ោង បន្ទាប់ត្រូវលាងសំអាតគ្រាប់ឲ្យស្អាត ចំនួន ៣-៤លើក មុនពេលផ្អាប់ត្រាំគ្រាប់ពូជ។ ការផ្អាប់ត្រូវយកក្រណាត់ជ្រលក់ទឹកឲ្យជោកយកមកខ្ចប់គ្រាប់នោះហើយកប់ទៅក្នុងដីសើមៗរយៈពេល ១យប់។ មុនដាំត្រូវយកគ្រាប់ពូជមកលាយជាមួយនឹងថ្នាំសម្លាប់ផ្សិតប្រភេទកាប់តង់,ស៊ីណែប,ម៉ង់កូសែប **ក្នុងកំរិត២% ឬ ១គក្រគ្រាប់ពូជបរិមាណថ្នាំកន្លះស្លាប ព្រាបាយ** ច្របល់ឲ្យសព្វយកទៅដាំដោយប្រើចន្លោះគុម្ព២៥ស.ម ចន្លោះ ជួរ៦០ស.ម ជម្រៅ២-៣ស.ម គ្រាប់ក្នុងមួយគុម្ព ហើយគ្របពីលើដោយកំណាត់ចំបើងខ្ចីៗ ឬជីធម្មជាតិពុករលួយល្អ វិធីនេះគឺដាំឲ្យត្រសក់ឡើងតោងចំណារបញ្ឈរ ប៉ុន្តែការដាំឲ្យវារលើដីត្រូវប្រើចន្លោះជួរ៨០ស.ម ចន្លោះគុម្ព ៥០ស.ម, ៣-៤គ្រាប់ ក្នុងមួយគុម្ពតែគ្របគុម្ពដូចគ្នា ។ ក្រោយពីដាំភ្លាមត្រូវពិនិត្យមើលសំណើមដី កាលណាដីស្ងួតខ្លាំងត្រូវតែស្រោចទឹកក្រោយដាំ ហើយដើម្បីឲ្យត្រសក់ដុះស្មើគ្នាងាយថែទាំ ។ ក្រោយពីដាំរយៈពេល៣ទៅ ៤ថ្ងៃ ក្នុងលក្ខខណ្ឌអាកាសធាតុពេលថ្ងៃ ៣០អង្សាសេ និងពេលយប់ ១៨-២០អង្សាសេ ធ្វើឲ្យត្រសក់លូតលាស់លឿន។





*៥.របៀបស្រោចស្រព*

ដំណាំត្រសក់ជាប្រភេទដំណាំត្រូវការទឹកជាប្រចាំ ប៉ុន្តែសំណើមដីមិនលើសពី៥០-៧០%ឡើង។ សេចក្ដីត្រូវការទឹកចែកចេញជាបីវគ្គ ៖

- **វគ្គលូតលាស់** : ចាប់ពីត្រសក់ដុះរហូតដល់ត្រសក់បោះដៃ និងមានផ្កាក្រពុំវាត្រូវការសំណើមដីជាមធ្យមប្រមាណ ពី៥០-៦០% ។ របៀបស្រោចដោយបាញ់ទឹកពីលើល្អជាងការស្រោចដោយបញ្ចូលតាមចន្លោះជួរ គឺ១ថ្ងៃម្ដង ឬ ២ដងទៅ តាមប្រភេទដី និងអាកាសធាតុ បរិមាណទឹកក្នុងវគ្គនេះមានប្រមាណ ពី **១៤០០ - ១៦០០ម៣/ហ.ត** ។
- **វគ្គបន្តពូជនិងផ្លែ** : ចាប់ពីត្រសក់មានអាយុពី១៥ថ្ងៃឡើងទៅវានឹងមានផ្កាឈ្មោលចេញតាមថ្នាំង ប៉ុន្តែមិនទាន់រីក។ វគ្គនេះត្រូវការសំណើមដីពី ៦០-៧០% គឺជាវគ្គដែលត្រូវការទឹកច្រើនជាងគេរហូតដល់ត្រសក់មានអាយុ ៣០-៤០ថ្ងៃក្រោយដាំ ប៉ុន្តែការស្រោចដោយបញ្ចូលតាមចន្លោះរងមួយអាទិត្យ២-៣ លើកជាការល្អ ព្រោះការស្រោចដោយបាញ់ទឹកពីលើធ្វើឲ្យប៉ះពាល់ដល់ការបន្តពូជបរិមាណទឹកសរុប ក្នុងវគ្គនេះមានពី **១៨០០ ទៅ ២០០០ម៣/ហ.ត** ។
- **វគ្គចេញផ្លែ** : ១០០% ចាប់ពីការប្រមូលផល ១-២លើក ត្រសក់ត្រូវការសំណើមដីទាបមកវិញ គឺពី ៥០-៦៥% កាលណាការបញ្ចូលទឹកលើសពីនេះធ្វើឲ្យត្រសក់ចាប់ប្រែព៌ណ៌ពីបៃតងទៅលឿង ។